វាយសារឡើងវិញបកប្រែពីឯកសារផ្លូវការ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១១ អនក្រ ១៩ វិច្ឆិកា ១៩៩៣

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅ នៃអាជ្ញាធរអាកាសចរស៊ីវិលកម្ពុជា
# រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ វរ្ម័ន ព្រះចៅក្រុងកម្ពុជា ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣
- យោងតាមការចាំបាច់

## សំរេច

**មាត្រា ១.-**

អាជ្ញាធរអាកាសចរណ៍ស៊ីវិលកម្ពុជា ជាភាសាបារាំងហៅថា Autorité de l'Aviation Civile du Cambodge សរសេរកាត់ "A.A.C.C" បានបង្កើតឡើងក្នុងគោលបំណងរៀបចំឡើងវិញ នូវគ្រប់សកម្មភាព នៃអាកាសចរណ៍ស៊ីវិល ដែលមានកន្លងមក និងឈានទៅអនុវត្តនយោបាយ សេរីភាវូបនីយកម្ម ផ្នែកអាកាសចរណ៍ ដោយផ្អែកលើមូលដ្ឋាន នៃការប្រកួតប្រជែង និងមាន ប្រសិទ្ធភាព។

នយោបាយសេរីភាវូបនីយកម្មនេះ គឺជាមូលដ្ឋានសំរាប់អនុញ្ញាត អោយផ្នែកអាកាសចរណ៍ស៊ីវិល កម្ពុជា បើកទ្វារចំហរចំពោះសកលលោកទាំងមូល ព្រមទាំងឆ្លើយតប បានទៅនឹងកំណើននៃចរាចរផ្លូវអាកាស និងចំនួនអ្នកធ្វើដំណើរកាន់តែច្រើនឡើង។

ការដាក់ផ្នែកនេះ អោយមានសេវាកម្មដ៏ត្រឹមត្រូវ លើផ្នែកបច្ចេកទេសប្រកបដោយប្រសិទ្ធភាព គឺជាការចាំបាច់ដាច់ខាត សំដៅទាក់ទាញក្រុមហ៊ុនអាកាសចរណ៍ ជាច្រើនអោយចូលមកកម្ពុជា។

**មាត្រា ២.-**

អាជ្ញាធរអាកាសចរណ៍ស៊ីវិលកម្ពុជា មានរចនាសម្ព័ន្ធដូចតទៅ:

- អាជ្ញាធរអាកាសចរណ៍ស៊ីវិលកម្ពុជា ស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ របស់ទីស្តីការគណៈរដ្ឋមន្ត្រី។

- អាជ្ញាធរអាកាសចរណ៍ស៊ីវិលកម្ពុជា ដឹកនាំដោយប្រធានមួយរូប មានឋានៈជាអនុរដ្ឋលេខាធិការ និង សមាជិកមួយចំនួនទៀត ដែលត្រូវតែងតាំងឡើងដោយរាជរដ្ឋាភិបាលកម្ពុជា ។
- ប្រធានអាជ្ញាធរអាកាសចរណ៍ស៊ីវិលកម្ពុជា មានអគ្គនាយកមួយរូប ព្រមទាំងអគ្គនាយករង ពីររូបទៀតជាជំនួយការ ។
- អគ្គនាយករងមួយរូបទទួលបន្ទុកកិច្ចការអាកាសចរណ៍ស៊ីវិល និងអគ្គនាយករងមួយរូបទៀតទទួល បន្ទុកកិច្ចការគ្រប់គ្រង និងកិច្ចការរដ្ឋបាល នៃអាកាសយានដ្ឋាន ។
- អាជ្ញាធរអាកាសចរណ៍ស៊ីវិលកម្ពុជា ត្រូវមានគណៈកម្មការមួយទទួលបន្ទុកការងារវិនិយោគ និង អភិបាលហិរញ្ញវត្ថុមួយរូប ។

**មាត្រា ៣.–**

មុខងាររបស់អាជ្ញាធរអាកាសចរណ៍ស៊ីវិលកម្ពុជា មានដូចតទៅ:

អាជ្ញាធរអាកាសចរណ៍ស៊ីវិលកម្ពុជា ត្រូវខិតខំយកចិត្តទុកដាក់អោយបានល្អប្រសើរ ទៅលើគ្រប់ផ្នែកក្នុងការងារអាកាសចរណ៍ស៊ីវិល តាំងពីការត្រួតពិនិត្យលើចរាចរហោះហើរ រហូតដល់ការគ្រប់គ្រងអាកាសយានដ្ឋាននៅទូទាំងប្រទេស:

- ដឹកនាំ និងត្រួតពិនិត្យអាជ្ញាធរអាកាសយានដ្ឋានទូទាំងប្រទេស ។
- ដឹកនាំគ្រប់គ្រងអាជ្ញាធរ នៃអគ្គនាយកដ្ឋានអាកាសចរណ៍ស៊ីវិលកម្ពុជា ។
- បង្កើតបណ្តាសេវាកម្ម លើការងារត្រួតចរាចរហោះហើរ ។
- ផ្តល់ ឬសំរបសំរួលកិច្ចប្រតិបត្តិការរុករក និងជួយសង្គ្រោះយន្តហោះ ដែលមានគ្រោះអាសន្ន ។
- ផ្តល់ជំនួយចាំបាច់ អោយអាជ្ញាធរអាកាសយានដ្ឋាន ដើម្បីបង្ការ និងពន្លត់អគ្គីភ័យ ។
- ជួយអភិវឌ្ឍន៍ដល់ការងារដឹកជញ្ជូនតាមផ្លូវអាកាស ដោយកំណត់អោយមានបទបញ្ញត្តិ និង វិធានការ ដើម្បីជំរុញដំណើរការទៅមុខ នៃអាជ្ញាធរអាកាសចរណ៍ស៊ីវិលកម្ពុជា ។
- ជូនយោបល់រាជរដ្ឋាភិបាល អំពីកិច្ចការអាកាសចរណ៍ស៊ីវិល ។
- ធ្វើសកម្មភាពនៅលើឆាកអន្តរជាតិ ក្នុងនាមជាតំណាងអាជ្ញាធរជាតិ លើវិស័យអាកាសចរណ៍ស៊ីវិល ។

**មាត្រា ៤.–**

បទបញ្ញត្តិទាំងឡាយណាដែលមានន័យផ្ទុយពីអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥.-**

សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីបណ្ដាក្រសួងដែលពាក់ព័ន្ធ និងប្រធានអាជ្ញាធរអាកាសចរណ៍ស៊ីវិលកម្ពុជា មានភារកិច្ចអនុវត្ត អនុក្រឹត្យនេះ តាមភារកិច្ចរៀងៗ ខ្លួន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ ១៩៩៣

ជ. រាជរដ្ឋាភិបាល

**នាយករដ្ឋមន្ត្រីទី ១**
**សម្ដេចក្រុមព្រះ នរោត្តម រណឫទ្ធិ**

**នាយករដ្ឋមន្ត្រីទី ២**
**ហ៊ុន សែន**